# បទអន្តរាគមន៍
## របស់ឯកឧត្តម ម៉ោញ សាផាន
## អនុប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា
## ថ្លែងក្នុងសន្និសីទស្តីពី ការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជន
## " ផលប៉ះពាល់នៃអំពើពុករលួយលើសង្គមកម្ពុជា "

នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៦

សូមគោរព ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា សមាជិក សមាជិកា រដ្ឋសភា ព្រឹទ្ធសភា

សូមគោរព លោក លោកស្រី អ្នកនាង កញ្ញា ជាភ្ញៀវជាតិ និងអន្តរជាតិ

ជាបឋមខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គសន្និសីទទាំងមូល និងសូមអរគុណដល់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ថ្ងៃនេះខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលមានឱកាសបានចូលរួមជាវាគ្មិននៅក្នុងសន្និសីទស្តីពី ការវាយតម្លៃអំពើពុករលួយក្នុងវិស័យឯកជន ជាពិសេសផលប៉ះពាល់នៃអំពើនេះទៅលើសង្គមកម្ពុជា ។ វិស័យឯកជន គឺជាផ្នែកមួយនៃកំណើនសេដ្ឋកិច្ចជាតិ ដែលជួយបង្កើននូវចំណូលថវិកាជាតិ ហើយវិស័យឯកជនក៏ជាផ្នែកចូលរួមចំណែកបង្កើតនូវការងារថ្មីៗ ដែលអាចស្រូបទាញនូវកំលាំងពលកម្ម ព្រមទាំងកាត់បន្ថយនូវភាពគ្មានការងារធ្វើ និងជួយលើកស្ទួយដល់ជីវភាពប្រជាពលរដ្ឋទៀតផង ។ ដើម្បីឱ្យវិស័យនេះមានការរីកចំរើនត្រូវមានការលើកកំពស់នូវវិស័យនេះ ហើយត្រូវបង្កនូវលក្ខណៈងាយស្រួល និង បង្កបរិយាកាស អំណោយផលដល់ផ្នែកឯកជន ។ ការលើកកំពស់ផ្នែកឯកជនឱ្យរីកចំរើន ទាមទារឱ្យមានការដោះស្រាយអំពើពុករលួយក្នុងផ្នែកនេះ ហើយនិងត្រូវកាត់បន្ថយនូវការិយាធិបតេយ្យ ។

ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ

អំពើពុករលួយក្នុងវិស័យឯកជនកើតឡើងដោយសារ ការចំណាយក្រៅផ្លូវការរបស់សហគ្រាស និងក្រុមហ៊ុនឯកជនទៅឱ្យមន្ត្រីសាធារណៈ ដើម្បីទទួលបានមកវិញនូវសេវាសាធារណៈ និងទំនាក់ទំនងល្អជាមួយមន្ត្រីសាធារណៈ ។ មូលហេតុដែលបណ្តាលឱ្យមានអំពើពុករលួយក្នុងវិស័យឯកជននេះ គឺ កើតឡើងដោយសារការអនុវត្តច្បាប់នៅមានកំរិតទាប ប្រាក់បៀវត្សមន្ត្រីសាធារណៈ នៅមានកំរិតទាប ប្រព័ន្ធអនុវត្តការងារគ្មានតម្លាភាព បក្សពួកនិយម គ្រួសារនិយម និង ខ្វះច្បាប់ប្រឆាំងអំពើពុករលួយមួយស្របតាមការវិវត្តន៍ប្រទេសជាតិនិងសង្គម។

ការិយាធិបតេយ្យក៏ជាកត្តាមួយដែលបង្ក ឱកាសដល់មន្ត្រីមានសមត្ថកិច្ចក្នុងការប្រព្រឹត្តិអំពើពុករលួយ ហើយការប្រព្រឹត្តិអំពើពុករលួយ ក្នុង ការិយាធិបតេយ្យ គឺជាការបង្កផលលំបាកដល់សហគ្រាស ក្រុមហ៊ុនឯកជន ជាពិសេស អ្នកវិនិ យោគបរទេស ។

អំពើពុករលួយតែងតែមានឥទ្ធិពលបញ្ច្រាសទិសគ្នាជាមួយនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច ទោះបីជាអំពើពុករលួយនេះកើតមានក្នុងវិស័យសាធារណៈ ឬវិស័យឯកជនក៏ដោយ ។ កាលបើមានអំពើពុករលួយកើតមាននៅក្នុងវិស័យឯកជន គឺនាំឱ្យចំណូលថវិកាជាតិដែលបានពីវិស័យនេះ នឹងមានការថយចុះ ដោយសារការចំណាយក្រៅផ្លូវការ ម្យ៉ាងទៀតអាចនឹងរារាំងការវិនិយោគទុននានា ឬការវិនិយោគទុននោះទទួលបានផលតិច វិនិយោគទុនភាគច្រើន ច្រើនតែលិចលង់ ហើយមានការខកចិត្ត នឹងបរិស្ថាននៃប្រទេសមួយ ។ យ៉ាងណាមិញប្រទេសកម្ពុជាយើង អំពើពុករលួយនៃវិស័យ នេះអាចកើតមានឡើងនៅគ្រប់ពេល និងគ្រប់ទីកន្លែង ហើយមានលក្ខណៈស្មុគស្មាញ ការចំណាយក្រៅផ្លូវការរបស់អាជីវករ សហគ្រាស ក្រុមហ៊ុន និង រោងចក្រនានាមានកំរិតខ្ពស់ ដែលធ្វើឱ្យប៉ះពាល់ដល់ការប្រមូលពន្ធ។ តាមការសិក្សាស្រាវជ្រាវ គេរកឃើញអំពើពុករលួយវិស័យឯកជនក្នុងឆ្នាំ ២០០៥ នេះមានរហូតដល់ ៣៣០ លានដុល្លា ថវិកាដែលបាត់បងនេះអាចយកមកប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចបានមួយផ្នែកធំ ដែលក្នុងនោះយើងអាចពង្រឹងរដ្ឋបាលសាធារណៈ ការតម្លើងប្រាក់បៀវត្សរ៍មន្ត្រីរាជការអាចទទួលយកបាន ពី ១០០ ទៅ ១៥០ ដុល្លាសហរដ្ឋអាមេរិចក្នុងមួយខែ។ ចំនួនប្រាក់បៀវត្សរ៍នេះអាចអោយមន្ត្រីរាជការរស់បានជាមធ្យម ។ ម្យ៉ាងវិញទៀតអំពើពុករលួយនេះនាំឱ្យមានការរារាំងដល់ការវិនិយោគទុននានា ឬ ការវិនិយោគទុននោះទទួលបានផលតិច ដូច្នេះការផ្តល់ប្រាក់បៀវត្សរ៍ដល់កម្មករមានកំរិតទាប ឬ វិនិយោគទុនឈប់បណ្តាក់ទុននាំឱ្យ កម្មករភាគច្រើនគ្មានការងារធ្វើ ហើយនឹងប៉ះពាល់ដល់ ជីវភាពរបស់ពួកគាត់ ។

ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា ជាភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ !

នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារ ២០០៥ និង ទិសដៅ ឆ្នាំ ២០០៦ របស់ក្រសួងទំនាក់ទំនងរដ្ឋសភា- ព្រឹទ្ធសភា និង អធិការកិច្ច បានបង្ហាញអោយឃើញថាមានភាពមិនប្រក្រតីមួយចំនួនកើតឡើងក្នុងស្ថាប័នរដ្ឋដែលបណ្តាលអោយបាត់បង់ចំណូលរបស់រដ្ឋ។ ជាមួយគ្នានោះបានរកឃើញមានប្រាក់ដែលសាខាគយខ្លះប្រមូលបានទុកនៅក្រៅបេឡា។ ក្នុងឆ្នាំ ២០០៣ សហគ្រាសក្រុមហ៊ុនជាប់ពន្ធមាន ៩១៩៦ ក្រុមហ៊ុន ប៉ុន្តែបង់ប្រាក់បានតែ ៣៨៣៩ក្រុមហ៊ុន ប៉ុណ្ណោះ ។ ក្នុងឆ្នាំ ២០០៤ សហគ្រាស ក្រុមហ៊ុន ជាប់ពន្ធ ៦០៧២ក្រុមហ៊ុន តែបង់បានតែ ៣៩៤១ក្រុមហ៊ុនប៉ុណ្ណោះ ។

កត្តាដូចបានរៀបរាប់ទាំងនេះ សុទ្ធតែជាអំពើអសកម្មដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះសង្គមជាតិទាំងមូល។

អង្គសន្និសីទយើងបានពិភាក្សាអស់រយៈពេលជិតមួយថ្ងៃមកហើយឃើញថាសន្និសីទបានផ្សព្វផ្សាយអំពីរបកគំហើញនៃការសិក្សាអំពីអំពើពុករលួយក្នុងវិស័យឯកជន ព្រមទាំងជាវេទិកាដ៏មានសារៈសំខាន់មួយដែលបានពិភាក្សាវែកញែក ផ្លាស់ប្តូរយោបល់គ្នា រិះរកវិធីសាស្ត្រ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយអំពើពុករលួយក្នុងវិស័យសាធារណៈ ក៏ដូចជាក្នុងវិស័យឯកជន ។ អនុសា-សន ដែលឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា បានលើកឡើងនាឱកាសនេះ គឺជាសក្ខីភាពមួយដែល ស បញ្ជាក់ឱ្យឃើញថា អង្គសន្និសីទមានឆន្ទៈមោះមុតក្នុងការ ចូលរួមចំណែកកាត់បន្ថយអំពើពុករលួយ ដែលកើតមានឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងវិស័យឯកជន ។ អនុសាសន៍ទាំងនេះមានសារៈសំខាន់យ៉ាងខ្លាំងដើម្បី បញ្ចូលក្នុងសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។

ក្នុងនាមខ្ញុំជាតំណាងរាស្ត្រ និងជាអនុប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា សូមគាំទ្រនូវអនុសាសន៍ដែលបានលើកឡើងដោយអង្គសន្និសីទនាឱកាសនេះ ដើម្បីធ្វើជាឧបករណ៍មួយចូលរួមចំណែកក្នុងការកាត់បន្ថយអំពើពុករលួយ ដែលកើតមានឡើងក្នុងរដ្ឋបាលសាធារណៈ ក៏ដូចជាក្នុងវិស័យឯកជន ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ដែលបានផ្តល់នូវបទពិសោធន៍ និងអនុសាសន៍ល្អៗជាច្រើន ហើយខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា នឹងខិតខំបន្តប្រឹងប្រែងតាមគ្រប់មធ្យោបាយ ក្នុងការចូលរួមទប់ស្កាត់នូវអំពើពុករលួយ ដែលកើតមានឡើងនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យបានរីកចំរើន ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធិពរជ័យជូនដល់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាង កញ្ញា សូមទទួលបានជោគជ័យគ្រប់ភារកិច្ច និង ជួបប្រទះនូវពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ !**